**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤០ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញ ក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតតែមប្រិ៍សារពើពន្ធ

- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៩១ ស្ដីពីការប្រមូលពន្ធតែមប្រិ៍សារពើពន្ធ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

តារាងពន្ធតែមប្រិ៍សារពើពន្ធ ត្រូវបានកំណត់និងកែសម្រួល ដូចខាងក្រោម÷

**ក. លិខិតគតិយុត្ត**

ពន្ធតែមប្រិ៍សារពើពន្ធ ត្រូវអនុវត្តចំពោះលិខិតគតិយុត្ត តាមប្រភេទ និងអត្រា ដូចខាងក្រោម÷

| **លេខរៀង** | **ប្រភេទលិខិត** | **អត្រាពន្ធ** |
|---|---|---|
| ១ | លិខិតស្នើសុំចូលរៀនមធ្យមសិក្សា | 0 ៛ |
| ២ | លិខិតស្នើសុំប្រឡងយកសញ្ញាបត្រ | 0 ៛ |
| ៣ | លិខិតស្នើសុំចូលរៀន និង ប្រឡងចូលរៀននៅគ្រឹះស្ថានអប់រំ ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងនិងក្រៅប្រទេស | 0 ៛ |
| ៤ | លិខិតស្នើសុំចូល និង ប្រឡងចូលធ្វើការ | 0 ៛ |
| ៥ | លិខិតថ្កោលទោស | 0 ៛ |
| ៦ | លិខិតស្នើសុំប្រឡងបើកបររថយន្ត/ជលយានយន្តគ្រប់ប្រភេទ | 0 ៛ |
| ៧ | លិខិតស្នើសុំចូលដេញថ្លៃឡូតិ៍នេសាទ-ព្រៃគុប | 0 ៛ |
| ៨ | លិខិតស្នើសុំបង្កើតក្រុមហ៊ុន អាហារ៍ណ-នីហរ៍ណ សណ្ឋាគារ វិនិយោគទុនបរទេស | 0 ៛ |
| ៩ | លិខិតស្នើសុំប្រកបអាជីវកម្មផ្សេងៗ | 0៛ |
| ១០ | លិខិតស្នើសុំផ្តល់ស្លាកលេខសម្គាល់យានយន្ត/ជលយានយន្តគ្រប់ប្រភេទ | 0 ៛ |
| ១១ | លិខិតស្នើសុំផ្សេងៗ | 0 ៛ |
| ១២ | ពាក្យបណ្តឹងគ្រប់ប្រភេទ | 0 ៛ |
| ១៣ | លិខិតបញ្ជាក់កិរិយាមារយាទ ប្រវត្តិរូប<br>បញ្ជាក់ទីលំនៅ "ដើម ឬ ចម្លង" | 0 ៛ |

| | | |
|---|---|---|
| ១៤ | សំបុត្រកំណើត "ដើម ឬ ចម្លង" | 0 ៛ |
| ១៥ | សំបុត្រមរណភាព "ដើម ឬ ចម្លង" | 0 ៛ |
| ១៦ | សំបុត្រអាពាហ៍ពិពាហ៍ "ដើម ឬ ចម្លង" | 0 ៛ |
| ១៧ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា "ដើម ឬ ចម្លង" | 0 ៛ |
| ១៨ | ប័ណ្ណសម្គាល់ត្រីចក្រយាន | 0 ៛ |
| ១៩ | ប័ណ្ណសម្គាល់ត្រីចក្រយានយន្ត | 0 ៛ |
| ២០ | ប័ណ្ណសម្គាល់ទោចក្រយានយន្ត | 0 ៛ |
| ២១ | ប័ណ្ណសម្គាល់រថយន្តគ្រប់ប្រភេទ | 0 ៛ |
| ២២ | ប័ណ្ណសម្គាល់ជលយាន | 0 ៛ |
| ២៣ | ប័ណ្ណសម្គាល់ជលយានយន្ត | 0 ៛ |
| ២៤ | ប័ណ្ណបើកបរយានយន្តគ្រប់ប្រភេទ | 0 ៛ |
| ២៥ | សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្មអាហរ័ណ-នីហរ័ណ សណ្ឋាគារ វិនិយោគទុនបរទេស | 0 ៛ |
| ២៦ | សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្សេងៗ | 0 ៛ |
| ២៧ | លិខិតបញ្ជាក់ លិខិតបកប្រែ | 0 ៛ |

**ខ. ប័ណ្ណប្រកាស**

ពន្ធតែមប្រិ៍សារពើពន្ធ ត្រូវអនុវត្តចំពោះប័ណ្ណប្រកាស តាមអត្រា ប្រភេទ និងទំហំផ្ទៃក្រឡា ដូចខាងក្រោម÷

| **លេខរៀង** | **ប្រភេទប័ណ្ណប្រកាស** | **អត្រាពន្ធ** | **លក្ខខណ្ឌបន្ថែម** |
|---|---|---|---|
| **ខ១. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា** | | | |
| ១ | មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៥០០៛/ទំព័រ | បើមានអក្សរបរទេស ១ ៥០០៛/ទំព័រ |
| ២ | មានផ្ទៃលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៧០០៛/ទំព័រ | បើមានអក្សរបរទេស ២ ១០០៛/ទំព័រ |
| **ខ២. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុ ផ្សេងៗ** | | | |

| | | | | |
|---|---|---|---|---|
| ៣ | មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៧០០៛/ផ្ទាំង | បើមានអក្សរបរទេស ២ ១០០៛/ផ្ទាំង | |
| ៤ | មានផ្ទៃលើសពី ៤០ ដល់ ១០០ ដេស៊ីម៉ែត្រក្រឡា "បើលើសពី ១០០ដេស៊ីម៉ែត្រក្រឡាត្រូវ គិតជាផ្ទាំងអក្សរ" | ១ ០០០៛/ផ្ទាំង | បើមានអក្សរបរទេស ៣ ០០០៛/ផ្ទាំង | |
| **១៣. ស្លាកអាជីវកម្មដ្ឋាននានា** | | | | |
| ៥ | គ្មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ១០០៛/ដម$^{២}$/ឆ្នាំ | ២០០៛ | បើមានអក្សរបរទេស ត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ៦ | គ្មានពន្លឺកែងដងផ្លូវសាធារណៈ | ១៥០៛/ដម$^{២}$/ឆ្នាំ | ៣០០៛ | |
| ៧ | មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ២០០៛/ដម$^{២}$/ឆ្នាំ | ៤០០៛ | |
| ៨ | មានពន្លឺកែងដងផ្លូវសាធារណៈ | ២៥០៛/ដម$^{២}$/ឆ្នាំ | ៥០០៛ | |
| **១៤. ផ្ទាំងអក្សរ ឬផ្ទាំងរូបភាព សម្រាប់គោលបំណងពាណិជ្ជកម្ម** | | | | |
| ៩ | គ្មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ៥០០៛/ដម$^{២}$/ឆ្នាំ | ១ ០០០៛ | បើមានអក្សរបរទេស ត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ១០ | គ្មានពន្លឺកែងដងផ្លូវសាធារណៈ | ៧០០៛/ដម$^{២}$/ឆ្នាំ | ១ ៤០០៛ | |
| ១១ | មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ៧០០៛/ដម$^{២}$/ឆ្នាំ | ១ ៤០០៛ | |
| ១២ | មានពន្លឺកែងដងផ្លូវសាធារណៈ | ១ ០០០៛/ដម$^{២}$/ឆ្នាំ | ២ ០០០៛ | |
| ១៣ | ដាក់ភ្ជាប់ តភ្ជាប់ ឬគូរផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូននានា | ១ ៥០០៛/ដម$^{២}$/ឆ្នាំ | ៣ ០០០៛ | |

**មាត្រា២.-**

ពន្ធតែមប្រើសារពើពន្ធ មិនអនុវត្តចំពោះប័ណ្ណប្រកាសដែលត្រូវបានផ្សព្វផ្សាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញ ដែលមានជាអាទិ៍ ដូចខាងក្រោម៖

- ស្លាកយីហោសម្រាប់អប់រំសង្គម ការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារព្រៃឈើនិងសត្វព្រៃ ការអប់រំច្បាប់ចរាចរណ៍
- ស្លាកយីហោរបស់អង្គការជាតិ និងអន្តរជាតិ
- ស្លាកយីហោរបស់ស្ថាប័នរដ្ឋ។

**មាត្រា៣.-**

ការអនុវត្តអនុក្រឹត្យនេះ អាចត្រូវបានកំណត់លម្អិត ឬណែនាំបន្ថែម ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.-**

អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលម្អនិងបំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រិ៍សារពើពន្ធ ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ